**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមេសា ឆ្នាំ២០១៨

នៅក្នុងខែមេសា ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០២លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៣ចំនួន ០២លើក និងសម័យប្រជុំពេញអង្គចំនួន០១លើក

-អញ្ជើញចូលរួមបើកសម័យប្រជុំដំបូងរបស់ព្រឹទ្ធសភា នីតិកាលទី៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ បន្ទាប់មកសម័យប្រជុំដំបូងក្រោមអធិបតីភាព ឯកឧត្តម **ម៉ុប ជិមហ៊ុយ** ប្រធានបណ្តោះអាសន្នព្រឹទ្ធសភា បានបោះឆ្នោតជ្រើសរើសសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ជាប្រធានព្រឹទ្ធសភា នីតិកាលទី៤ បន្តទៀត

-អញ្ជើញធ្វើសច្ចាប្រណិធាន នៅចំពោះព្រះភក្ត្រព្រះមហាក្សត្រ ព្រះភក្ត្រនៃព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង

-អញ្ជើញទទួលព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះអង្គស្តេចយាងមកដល់មាតុភូមិវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អញ្ជើញជូនព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គស្តេចយាងពីមាតុប្រទេស ដើម្បីបំពេញព្រះរាជទស្សនកិច្ចនៅព្រះរាជាណាចក្រជប៉ុន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អនុញ្ញាតឲ្យឯកឧត្តមសេនីយ៍ទោ **ហ្វាម វ៉ាន់យី** ប្រធាននយោបាយបញ្ជាការដ្ឋាន យោធភូមិភាគទី៧ និងគណៈប្រតិភូ នៃកងទ័ពប្រជាជនវៀតណាម ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឲ្យលោកបណ្ឌិត Daniel Schumcking នាយកមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឲ្យលោក Guo Qing អនុប្រធានក្រុមហ៊ុន Pacific Construction international Group ព្រមទាំងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឲ្យកីឡាករ កីឡាការិនី ទទួលជ័យលាភីមេដាយមាស ចូលជួបសម្តែងការគួរសម

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធ និងបញ្ចុះខណ្ឌសីមាព្រះវិហារថ្មីវត្តឧត្តមសាមគ្គីរតនារាម (ហៅវត្តភូមិហ្វាំង) ស្ថិតក្នុងភូមិហ្វាំង ស្រុកវើនសៃ ខេត្តរតនគិរី

-អញ្ជើញជួបសួរសុខទុក្ខ លោកយាយ លោកតា និងបងប្អូនប្រជាពលរដ្ឋនៅភូមិកណ្តាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ប្រកបដោយមនោសញ្ចេតនាសប្បាយរីករាយ ស្រឡាញ់រាប់អានយ៉ាងស្និទ្ធស្នាលបំផុត

-អញ្ជើញចុះសួរសុខទុក្ខឯកឧត្តម **ប៊ូ ថង** សមាជិកព្រឹទ្ធសភា នៅភូមិហ្វាំង ឃុំថុង ស្រុកវើនសៃ ខេត្តរតនគិរី

-អញ្ជើញនាំយកទេយ្យវត្ថុ និងចង្ហាន់ទៅប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសកុសលជូនសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ ព្រមទាំងបុព្វការីជន ដែលបានពលីជីវិតក្នុងបុព្វហេតុកសាងជាតិមាតុភូមិ នៅវត្តមុនីប្រសិទ្ធវង្ស សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

-អញ្ជើញប្រារព្ធពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ដើម្បីឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធមហាឧបាសក **គង់ ខាត់** និងបុណ្យអាយុវឌ្ឍនកម្មពូនភ្នំខ្សាច់មហាឆាក(បុព្វការីជន)ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី នៅវត្តសុវណ្ណគិរី-ដើងថ្នុក ភូមិដើងថ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-អញ្ជើញនាំយកនូវបច្ច័យ ទេយ្យវត្ថុ និងគ្រឿងឧបភោគបរិភោគប្រគេន សម្តេចព្រះពោធិវង្ស **អំ លឹមហេង** ព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តចំពុះក្អែក ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសក **គង់ ខាត់** និងបុព្វការីជន ញាតិកាទាំង៧សន្តានរបស់សម្តេច និងលោកជំទាវ នៅសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញនាំយកនូវបច្ច័យ ទេយ្យវត្ថុ និងគ្រឿងបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធ បុព្វការីជន និងញាតិកាទាំង៧សន្តាន នៅភូមិកណ្តាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងចូលរួមរំលែកទុក្ខក្រុមគ្រួសារសព ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅគេហដ្ឋានលេខ១៦៨ ផ្លូវ៤៦៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៨ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា ប្បាន** :

-ទទួលការកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចូលរួមក្នុងពិធីបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៤ និងពិធីសច្ចាប្រណិធាន ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។ ព្រឹទ្ធសភាបានបោះឆ្នោតជ្រើសរើសឯកឧត្តម **នៃ ប៉េណា** ជាអនុប្រធានទី១ព្រឹទ្ធសភា នីតិកាលទី៤បន្តទៀត

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទការប្រកួតកីឡាបាល់ទាត់ពានរង្វាន់ឯកឧត្តម **នៃ ប៉េណា** អនុប្រធានទី១ ព្រឹទ្ធសភា ដែលមានការចូលរួមពីសមាជិករដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល ទីប្រឹក្សា និងថ្នាក់ដឹកនាំជុំវិញខេត្តកំពត នៅពហុកីឡដ្ឋានបាល់ទាត់ខេត្តកំពត

-អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **វ៉ាស៊ឹម សំរិទ្ធិ** ទីប្រឹក្សារាជរដ្ឋាភិបាល នៅគេហដ្ឋានលេខ៧៩ ផ្លូវលេខ៣ បុរីពិភពថ្មីសំរោងអណ្តែត រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូសមាជិកព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅគេហដ្ឋានលេខ១៦៨ ផ្លូវ៤៦៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១០៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៦៨ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ ចំនួន០១លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមក្នុងពិធីបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៤ និងពិធីសច្ចាប្រណិធាន ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។ ព្រឹទ្ធសភាបានបោះឆ្នោតជ្រើសរើសឯកឧត្តម **ទេព ងន** ជាអនុប្រធានទី២ ព្រឹទ្ធសភា នីតិកាលទី៤

-អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្តចម្រើនសិរីមង្គល ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

-អញ្ជើញជួបសំណេះសំណាលជាមួយលោក zhu xin yuan អគ្គនាយករងក្រុមហ៊ុនអគ្គិសនីស្ទឹងឫស្សីជ្រុំ ដើម្បីសិក្សាឈ្វេងយល់អំពីដំណើរការនៃការផលិតថាមពល និងការផ្គត់ផ្គង់ថាមពលអគ្គិសនី នៅក្នុងស្ថានីយ៍អគ្គិសនីស្ទឹងឫស្សីជ្រុំ នៅខេត្តកោះកុង

-អញ្ជើញជប់លៀងជូនគណៈប្រតិភូ ដែលមកបំពេញទស្សនកិច្ចឈ្វេងយល់ពីជីវភាព និងការរស់នៅរបស់ប្រជាពលរដ្ឋ រស់នៅតាមតំបន់ភ្នំ នៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-អញ្ជើញចូលរួមក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងពុទ្ធាភិសេក នៅវត្តឧត្តម-សាមគ្គីរតនារាម ស្ថិតក្នុងឃុំបានប៉ុង ស្រុកវើនសៃ ខេត្តរតនគិរី

-អញ្ជើញនាំយកទេយ្យវត្ថុ និងចង្ហាន់ទៅប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសកុសលជូនសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ ព្រមទាំងបុព្វការីជន ដែលបានពលីជីវិតក្នុងសម័យសង្គ្រាម នៅវត្តចន្ទបុរីវង្ស វត្តមុន្នីប្រសិទ្ធវង្ស និងវត្តព្រៃកប្រាំង

-អញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ មហាឧបាសក **គង់ ខាត់** បិតាក្មេករបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅវត្តសុវណ្ណគិរី-ជើងថ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-អញ្ជើញចុះសួរសុខទុក្ខឯកឧត្តម **ប៊ូ ថង** សមាជិកព្រឹទ្ធសភា នៅភូមិហ្វាំង ឃុំចុង ស្រុកវើនសៃ ខេត្តរតនគិរី

-អញ្ជើញពិសារបាយសាមគ្គីជាមួយអតីតសិស្សនិស្សិត ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលពីឯកឧត្តម នៅភោជនីយដ្ឋានឡឺសេអ៊ូល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៦ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ចំនួន០២លើក:**

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៨ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី អាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈ

២.កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣. សម័យប្រជុំពេញអង្គចំនួន០១លើក** :

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី អាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមេសានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

**៤.១.មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាលដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ ច្បាប់ ។

**៤.២. មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញចុះតាមដានឈ្វេងយល់ និងប្រមូលព័ត៌មាន នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង

-គណៈកម្មការទី៥ អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រែកជ្រៃធំ នៅស្រុកកោះធំ ខេត្តកណ្តាល ។

**៤.៣. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៥ករណី បញ្ជូនពាក្យបណ្តឹងទៅស្ថាប័នពាក់ព័ន្ធចំនួន០៦ករណី ទទួលលិខិតឆ្លើយតបពាក្យបណ្តឹងចំនួន០២ករណី ព្រមទាំងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន១៣ករណី និងតម្កល់ទុកមិនចាត់ការចំនួន០១ករណី

-អញ្ជើញជាគណៈអធិបតីក្នុងពិធីបើកអង្គសិក្ខាសាលាស្តីពី ការគ្រប់គ្រងសុខភាពសត្វ និងផលិតកម្មសត្វ

-អញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយគណៈប្រតិភូសហព័ន្ធនារីអ៊ុយក្រែន ដឹកនាំដោយលោកជំទាវ GERASYMENKO LEOKADA ប្រធានសហព័ន្ធនារីអ៊ុយក្រែន

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីភ្នំពេញចំនួន៦៥លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្ត

គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗ លើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៦លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ជា ចេដ្ឋ** អនុញ្ញាតឲ្យលោក Maxime JOHANET អ្នកស្ម័គ្រចិត្តនៅការិយាល័យហ្វ្រង់កូហ្វូនីព្រឹទ្ធសភា ដែលកំពុងសិក្សាអំពីទំនាក់ទំនងការងារព្រឹទ្ធសភាកម្ពុជាជាមួយ(PFWB) ចូលជួបពិភាក្សាការងារ

-ឯកឧត្តម **ជា ចេដ្ឋ** ជួបពិភាក្សាការងារជាមួយលោកGilles Johanet អគ្គរដ្ឋអាជ្ញាអមតុលាការគណនេយ្យ ដោយមានការចូលរួមពីលោក Serge Billini ទីប្រឹក្សាហ្វ្រង់កូហ្វូនីអមស្ថានទូតបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីបានផ្លាស់ប្តូរព័ត៌មានគ្នាអំពីភារកិច្ច មុខងារ សមត្ថកិច្ចតុលាការគណនេយ្យ និងអាជ្ញាធរសវនកម្ម ឯកឧត្តម Gilles Johanet បានយល់ព្រមទទួលគណៈប្រតិភូព្រឹទ្ធសភា ទៅទស្សនកិច្ចនៅតុលាការគណនេយ្យ

-ឯកឧត្តម **ប៊ូ ថង** អនុញ្ញាតឲ្យឯកឧត្តម **ប្រាស៊ីត សាយ៉ាស៊ីត** ឯកអគ្គរដ្ឋទូតឡាវប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងសហការី ចូលជួបសម្តែងការគួរសម

-ឯកឧត្តម **ម៉ាន់ ឈឿន** បានអញ្ជើញជួបពិភាក្សាការងារជាមួយលោក Likhit BHATRARAM ទីប្រឹក្សាអមស្ថានទូតព្រះរាជាណាចក្រថៃ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អំពីការបន្តចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឲ្យបានល្អ ព្រមទាំងការផ្លាស់ប្តូរសេដ្ឋកិច្ចឲ្យកាន់តែល្អប្រសើរ។

ថ្ងៃ អង្គារ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសា